# សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស
# ស្ថានភាពអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា
# ខែ ធ្នូ ឆ្នាំ ២០០២

ឯកសារសង្ខេបនេះនឹងផ្តល់នូវទស្សនៈទូទៅនៃធាតុពិត និងការបន្តគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ។ របាយការនេះផ្អែកលើការស៊ើបអង្កេតនិងការប្រមូលពតិមានដោយអង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (លីកាដូ)[1] ។

ការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា រួមមានទាំងវិធីតាមឃ្លាំមើល និងការបំភិតបំភ័យដោយពាក្យសំដី តាមរយៈការគំរាមកំហែងដោយចាប់ចងនិងឃុំឃាំង ប្រើអំពើហឹង្សាលើរាងកាយ និងការគំរាមកំហែងដល់អាយុជីវិត ដែលទង្វើទាំងនេះបានធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុវត្ថិភាពរបស់អ្នកការពារសិទ្ធិមនុស្ស និងលទ្ធភាពក្នុងការអនុវត្តន៏ការងាររបស់អ្នកទាំងនោះ ។ ផ្អែកលើពតិមានទាំងនេះ លីកាដូសូមគាំទ្រអោយមានចំណាត់ការរួមគ្នាមួយដោយសុំអោយមានការចូលរួមពីសំណាក់ក្រុមអង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិ រដ្ឋាភិបាលបរទេស និងម្ចាស់ទីភ្នាក់ងារផ្តល់ជំនួយនានាដើម្បីចាត់វិធានការណ៍លើការគំរាមកំហែងដែលមានក្នុងរាយការណ៏នេះ ។ សូមទាមទារអោយរាជរដ្ឋាភិបាលកម្ពុជាធ្វើការផ្តន្ទាទោសជនល្មើស និងឆ្លងតាមរយៈរបាយការនេះសុំអោយរាជរដ្ឋាភិបាលអនុវត្តន៏នូវការសន្យារបស់ខ្លួនចំពោះ សេរីភាពនៃការបង្កើតសមាគម សេរីភាពនៃការចូលរួមបញ្ចេញមតិផ្តល់កិច្ចការពារដល់អ្នកការពារសិទ្ធិមនុស្ស ដូចដែលមានចែងនៅក្នុងកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែលច្បាប់នេះត្រូវបានចុះហត្ថលេខាដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំ ១៩៩២ ។

អង្គការលីកាដូត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩២ ហើយមានមូលដ្ឋាននៅរាជធានីភ្នំពេញ និងមានការិយាល័យ នៅតាមបណ្តាខេត្តចំនួន ១២ ទៀត។ ការងាររបស់លីកាដូ ជារួមមានការងាឃ្លាំមើលចំពោះករណីរំលោភសិទ្ធិមនុស្សជួយជនរងគ្រោះក្នុងការធ្វើបណ្តឹងទៅអាជ្ញាធរពាក់ព័ន្ធធ្វើការស៊ើបអង្កេត និងលើកកំពស់អោយមានការគាំទ្រតស៊ូមតិស្តីពីបញ្ហាសិទ្ធិមនុស្ស និងផ្តល់ការអប់រំសិទ្ធិមនុស្សដល់ក្រុមគោលដៅមួយចំនួន។ ការងាររបស់លីកាដូ ត្រូវបានបែងចែកចេញជា ៦ ការិយាល័យរួមមានការិយាល័យ

---

[1] ការសំភាសន៏ជាមួយ អ្នកស្រីសារ៉ា ខុម អង្គការឃ្លាំមើលសិទ្ធិមនុស្ស ប្រចាំអាស៊ី-ហេនរិក អាលហ្វ្រាម និង គាត បូផល -ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា-ជ្ជេសិន្ទ បាប៊ីរ លីកាដូ និង បុគ្គលិកផ្សេង ៧ទៀតនៅការិយាល័យស៊ើបអង្កេតលីកាដូ ។

អប់រំសិទ្ធិមនុស្ស ការិយាល័យការពារសិទ្ធិមនុស្ស ការិយាល័យការពារសិទ្ធិកុមារ ការិយាល័យការពារសិទ្ធិស្ត្រី ការិយាល័យក្រុមពេទ្យ និងការិយាល័យកម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម ។

## តើអ្នកណាជាអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ?

ការងារសិទ្ធិមនុស្ស ត្រូវបានអនុវត្តដោយសកម្មជនសិទ្ធិមនុស្សជាច្រើនដោយមានការចូលរួមពីសំណាក់មហាជនរួមមានព្រះសង្ឃ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស ដែលអាចជាជនសកម្មនៅក្នុងការលើកកំពស់និងការពារសិទ្ធិមនុស្ស រាប់ទាំងបុគ្គលិករបស់អង្គការសិទ្ធិមនុស្សដែលមានច្បាប់អនុញ្ញាតអោយអនុវត្តន៏ការងារច្បាស់លាស់ជាប្រចាំថ្ងៃរបស់គេដែលសំដៅលើការដោះស្រាយបញ្ហាសិទ្ធិមនុស្សជាមូលដ្ឋាន ។ លើសពីនេះទៅទៀតក៏នៅមានបុគ្គលិកមួយចំនួនទៀតដែលត្រូវបានអង្គការជ្រើសរើសអោយបំរើការងារ ឧទាហរណ៏ដូចជាអ្នកបកប្រែ អ្នកបើកបររថយន្តជាដើម ថ្វីត្បិតបើគេមិនបានអនុវត្តន៏ការងារស៊ើបអង្កេតសិទ្ធិមនុស្សផ្ទាល់ក្តី ប៉ុន្តែអ្នកទាំងនោះក៏ជាអ្នកដែលត្រូវទទួលរងការវាយប្រហារដោយសារតែគេមានការពាក់ព័ន្ធទៅនឹងអង្គការសិទ្ធិមនុស្សដែរ ។

ដើម្បីជាអត្ថប្រយោជន៏ ឯកសារសង្ខេបនេះនឹងផ្តោតទៅលើតែការគំរាមកំហែងមកលើអ្នកការពារសិទ្ធិដែលជាប់ពាក់ព័ន្ធផ្ទាល់ជាមួយនឹងការងារអង្គការសិទ្ធិមនុស្សតែប៉ុណ្ណោះ ដូចជាបុគ្គលិកទាំងឡាយដែលចូលរួមប្រឡូកក្នុងការដោះស្រាយករណីរំលោភសិទ្ធិមនុស្ស ដែលជាផ្នែកមួយក្នុងអណត្តិបេសកៈកម្មការងាររបស់គេ រួមមានបុគ្គលិករបស់ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ ក៏ដូចជាសកម្មជនអង្គការក្រៅរដ្ឋាភិបាល ឬសមាជិកបណ្តាញអង្គការក្រៅរដ្ឋាភិបាលដ៏ទៃទៀត ។ ប៉ុន្តែចំណុចដែលសំខាន់នោះគឺត្រូវកត់សំគាល់ពីអ្វីដែលបានរៀបរាប់ភាគច្រើននៅក្នុងឯកសារនេះប្រាកដជាបានកើតឡើងក្នុងក៏រិតខុសៗគ្នាមួយទូទាំងសង្គមស៊ីវិលដែលមានក្នុងប្រទេសកម្ពុជា ។ ចំពោះឯកសារនេះពាក្យដែលថា " អ្នកការពារសិទ្ធិមនុស្ស " មិនបានរាប់បញ្ចូលសមាជិកគណបក្សនយោបាយផងទេ ព្រោះស្ថានភាពនយោបាយរបស់អ្នកទាំងនោះអាចបណ្តាលអោយគេងាយប្រឈមមុខនឹងហរិភ័យដ៏ធ្ងន់ធ្ងរ ហើយហរិភ័យទាំងនោះរួមមានការប្រឈមមុខគ្រោះថ្នាក់ដល់អាយុជីវិត ដូចមានជាឧទាហរណ៏តាំងពីដើមរៀងរហូតមកទល់នឹងការបោះឆ្នោតឃុំសង្កាត់កាលពីខែ កុម្ភៈ ឆ្នាំ២០០២ កន្លងទៅនេះ នាពេលនោះមានអ្នកសកម្មជននយោបាយចំនួន១៧នាក់បានស្លាប់ នេះបើយោងតាមរបាយការណ៏របស់ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅកម្ពុជា[២] ។

---

[2] តំណាងពិសេសនៃអគ្គលេខាអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ ២០០២ ។ របាយការណ៏បោះ ឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០០២ ទំព័រ ១០ ។

## ចលនាសិទ្ធិមនុស្សនៅកម្ពុជា

សង្គមស៊ីវិលនៅកម្ពុជាបានតស៊ូជំនះនូវមតិកផ្ទត់គំនិត ដែលបន្សល់ទុកដោយរបបសាហាវយង់ឃ្នងនាឆ្នាំ ១៩៧៥-១៩៧៩ ដែលបានសំលាប់មនុស្សប្រមាណ ១,៧ លាននាក់នៅក្នុងសម័យនោះ ។ ដោយរបបនេះប្រព្រឹត្តិសកម្មភាពរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនៅទូទាំងប្រទេស រួមមានការបង្អត់អាហារ ការបង្ខិតបង្ខំអោយធ្វើការជាទំងន់ ការរំលោភសេពសន្ថវៈ ការធ្វើទារុណ្ណកម្មដ៏សាហាវ និងការសំលាប់យ៉ាងរង្គាល ។ ទោះបីជារបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ ទៅហើយក្តី សង្គ្រាមស៊ីវិលនៅបានបន្តរហូតមកដល់ចុងទសវត្ស ១៩៩០នេះ ដោយសារក្រុមភាគីនយោបាយផ្សេងៗបានច្បាំងគ្នាដើម្បីដណ្តើមអំណាច ។ ការបង្កើតអោយមានអ៊ុនតាក់នៅឆ្នាំ១៩៩២ បានធ្វើអោយសង្គមស៊ីវិលរស់ឡើងវិញ។ អង្គការអន្តរជាតិមួយចំនួនតូចដែលបំពេញបេសកកម្មនៅកម្ពុជានាអំឡុងទសវត្សឆ្នាំ ១៩៨០ ភាគច្រើនបំរើការងារផ្នែកជំនួយសង្គ្រោះ និងមនុស្សធម៌តែប៉ុណ្ណោះ ។ គំរោងកម្មវិធីការងារទាំងនោះ ពុំមែនជាគំរោងសំរាប់ជួយឧបត្ថមដល់ប្រជាជនស្រទាប់ថ្នាក់ក្រោមទេ តែជាគំរោងដែលស្របទៅនឹងអង្គការផ្តល់ជំនួយអន្តរជាតិ និងគំរោងរបស់រដ្ឋាភិបាល ដូចជាការស្តារហេដ្ឋារចនាសម្ព័ន្ធឡើងវិញជាដើម ។ អង្គការសិទ្ធិមនុស្សដំបូងបង្អស់មានសមាគមអាដហុក និងអង្គការលីកាដូ បានចាប់ផ្តើមប្រតិបត្តិការណ៍ការងារភ្លាមៗក្រោយពីមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសឆ្នាំ១៩៩១។ ជាសន្ទឹមៗ អង្គការសិទ្ធិមនុស្សបានចាប់ផ្តើមលើកកំពស់អោយមានការយល់ដឹងដល់សាធារណជន ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ក៏ដូចជាការធ្វើសកម្មភាពបន្ថែមទៀតលើការងារដែលទាក់ទងភាគច្រើនលើការតស៊ូមតិ ។ ក្នុងរយៈពេល ៥ឆ្នាំកន្លងទៅនេះ អង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិបានអនុវត្តន៏តួនាទីយ៉ាងធំធេង ជារួមមានការផ្តល់សេវាជាមូលដ្ឋានដល់ជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្ស ដូចជាផ្តល់ស្បៀងអាហារ ការផ្តល់ជំរកជ្រកនៅបណ្តោះអាសន្ន ការពារក្តីតាមផ្លូវច្បាប់ រួមមានការតស៊ូមតិ ការឃ្លាំមើលស្ថាប័នរដ្ឋាភិបាល ព្រមទាំងការរិះគន់គោលនយោបាយរដ្ឋាភិបាលដែលមិនស្របទៅនឹងបទដ្ឋានសិទ្ធិមនុស្ស ។ ចំនួនអង្គការក្រៅរដ្ឋាភិបាលបានបន្តកើនឡើងជាលំដាប់ ដែលក្នុងនោះរួមមាន អង្គការជាតិប្រមាណ ៨០០ និងអន្តរជាតិប្រមាណ ២០០ ថែមទៀតដែលទទួលបានការអនុញ្ញាតរហូតមកដល់ឆ្នាំ ២០០១ កន្លងទៅ នេះ [៣] ។

---

[3] អាដហុក ឆ្នាំ ២០០១ -ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ ២០០១ ទំព័រ ១០ ។

## ឧបសគ្គបច្ចុប្បន្នដែលសង្គមស៊ីវិលកម្ពុជាកំពុងប្រឈមមុខ

ភាពក្រីក្រជាបញ្ហាចម្បងនៅកម្ពុជា ដែលប្រទេសនេះមានផលិតផលជាតិសំរាប់មនុស្សម្នាក់ត្រឹមតែ ២៩៧ ដុល្លា អាមេរិកក្នុងមួយឆ្នាំប៉ុណ្ណោះ ។ កត្តានេះមិនត្រឹមតែបណ្តាលអោយមានបញ្ហាផ្នែកសុខភាព និងអត្រាមធ្យមភាគនៃអាយុរស់នៅមានកំរិតទាបប៉ុណ្ណោះទេ វាថែមទាំងបង្ករអោយមានការលំបាកជាច្រើនដែលសង្គមស៊ីវិលត្រូវប្រឈមមុខចូលរួមដោះស្រាយផងដែរ ។ ប្រព័ន្ធតុលាការនៅមានភាពទន់ខ្សោយ ហើយពោរពេញទៅដោយអំពើពុករលួយ ព្រមទាំងទទួលរងនូវឥទ្ធិពលពីភ្នាក់ងាររដ្ឋាភិបាលទៀតផង ។ លើសពីនេះទៅទៀតរដ្ឋាភិបាលបានគ្រប់គ្រងប្រព័ន្ធឃោសនាផ្សព្វផ្សាយមួយភាគធំ ។ កងកំលាំងប្រដាប់អាវុធមានកងទ័ពនគរបាលជាដើមបានបង្ករការកាប់សំលាប់យ៉ាងច្រើនរួមទាំងករណីពាក់ព័ន្ធនយោបាយ និងករណីមិនពាក់ព័ន្ធនយោបាយ ។ កត្តាទាំងនេះរួមនឹងកង្វះគោលនយោបាយសំរាប់ដោះស្រាយបញ្ហាសិទ្ធិមនុស្សកង្វះការហ្វឹកហ្វឺនអប់រំដល់អាជ្ញាធររដ្ឋបញ្ហានិទ្ទណ្ឌភាពកង្វះសហប្រតិបត្តិការល្អរវាងស្ថាប័នរដ្ឋាភិបាលនិងក្រុមការងារសិទ្ធិមនុស្ស កត្តាទាំងនេះអាចក្លាយទៅគ្រោះថ្នាក់ជាទីបំផុតក្នុងកិច្ចខិតខំប្រឹងប្រែង រួមចំណែកក្នុងទិដ្ឋភាពនៃកិច្ចការពារជនរងគ្រោះដោយហេតុផលអំពើរំលោភសិទ្ធិមនុស្ស ។

## ធាតុពិត និងការបន្តគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្ស

ពត៌មានដែលទទួលបានពីអង្គការលីកាដូ និងអង្គការសិទ្ធិមនុស្សផ្សេងៗទៀតបានបង្ហាញនូវបែបផែននៃការបំភិតបំភ័យនិងការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សកម្ពុជាដ៏ជាក់ច្បាស់ ដែលបណ្តាលអោយមានកង្វល់ខ្លាំងថែមទៀតអំពីស្ថេរភាពការងារសិទ្ធិមនុស្សទៅថ្ងៃអនាគត ។ ការគំរាមកំហែងអ្នកការពារសិទ្ធិមនុស្សក្នុងកំឡុងពេល ៥ ឆ្នាំ កន្លងមករួមមាន[៤] ។

- ការគំរាមកំហែងមកលើសេរីភាពក្នុងការចូលជាសមាគម និងសេរីភាពនៃការបញ្ចេញមតិ ។
- ល្បិចបំភិតបំភ័យជារួមមានដូចជាការប្រមូលស្នាមមេដៃពីប្រជារាស្ត្រ ដែលបញ្ហានេះតែងតែបានប្តឹងចូលមកការិយាល័យអង្គការសិទ្ធិមនុស្សជាប្រចាំ ។
- ការគំរាមរំខានតាមរយៈទូរស័ព្ទ ។

[4] ចំពោះពត៌មានបន្ថែមសូមអានរបាយការណ៏ឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ " ការគំរាមកំហែងដែលបានដឹងឬរបាយការណ៏ដោយអ្នកការពារសិទ្ធិមនុស្ស ។

- ការគំរាមដោយពាក្យសំដីប្រមាណមើលងាយមើលថោកជាដើម[៥] ។
- លក្ខណៈគំរាមកំហែងដោយការជិះម៉ូតូតាម ឬជនស្លៀកពាក់ជាស៊ីវិលលបលួចតាមឃ្លាំមើលជុំវិញការិយាល័យបំពេញការងារ ។
- គំរាមចាប់ឃុំឃាំងខ្លួនពីសំណាក់នគរបាល និងអាជ្ញាធររដ្ឋាភិបាល ។
- គំរាមចាប់ឃុំឃាំងដោយខុសច្បាប់ ។
- គំរាមកំហែងដោយការចាត់វិធានការណ៏ផ្លូវច្បាប់ទាំងបំពាន និងតាមអំពើចិត្តនៃអំណាច ។
- ការផ្ញើលិខិតព្រមាន ។
- ការបង្ករអោយមានរបួសស្នាមលើរូបរាងកាយ ។
- ការប្រព្រឹត្តិអំពើផ្តេសផ្តាសមិនគប្បីតាមមធ្យោបាយងងឹត ។
- ការចាប់ដាក់ពន្ធនាគារ ឃុំឃាំង និងការកាត់ក្តីតាមអំពើចិត្ត ព្រមទាំងការគំរាមកំហែងប្រមាណដល់អាយុជីវិតជាដើម ។ល។

នៅពេលដែលយើងរកប្រភពអត្តសញ្ញាណឃើញជនល្មើសដែលប្រព្រឹត្តិអំពើគំរាមកំហែងនេះភាគច្រើនរួមមានមន្ត្រីនគរបាល មន្ត្រីយោធា មន្ត្រី ថ្នាក់ឃុំ មន្ត្រីនៃមន្ទីរនានាតាមបណ្តាខេត្តក្រុង អាជ្ញាធរស្រុក និងមន្ត្រីស៊ុរិយោដី អភិបាលស្រុក និងនគរបាលជុំវិញស្រុកព្រមទាំងមន្ត្រីតុលាការផងដែរ[៦] ។

## ការឃ្លាំមើល

សូរសំលេងដែលចេញជាពាក្យសំដីគំរាមកំហែងគឺជាយុទ្ធសាស្ត្របំភិតបំភ័យដ៏សាមញ្ញមួយ ។ ភាគច្រើនជនល្មើសប្រព្រឹត្តិអំពើគំរាមកំហែងទាំងនេះគឺជាជនមិនស្គាល់មុខ ដូចជាករណីគំរាមកំហែងអនាមឹកតាមរយៈទូរស័ព្ទជាដើម ។

---

[5] ការគំរាមកំហែងដោយពាក្យសំដីដែលអាចត្រូវបានបកស្រាយយ៉ាងច្បាស់នៅក្នុងភាសា ដើម្បីការពារជនល្មើស ប៉ុន្តែ ទោះជាការបកស្រាយយ៉ាងណា ក៏អត្ថន័យនៃការគំរាមកំហែងនៅតែមានន័យច្បាស់លាស់ដដែល ។ នៅក្នុងភាសាខ្មែរការគំរាមកំហែងអាចត្រូវបានសនម្មតិដោយអត្ថន័យជាច្រើនអាស្រ័យទៅតាមវ៉ែយ ស្ថានភាព និងការប្រើគ្រាមភាសារបស់មនុស្សជាដើម ដែលអាចធ្វើអោយភាគីគំរាមអាចលាក់បាំងនូវចេតនាគំរាមរបស់គេបានក្នុងភាសាដែលពុំមែនជាពាក្យគំរាម។ ឧ. ឃ្លាដូចជា" ឯងចាំមើល " ឬ មិនអីទេឯង ។ល។ (ចាំមើលនឹងមានអ្វីកើតឡើងនៅថ្ងៃក្រោយ) ។

[6] Infra note 5 ទំព័រ ២០ ។

សេចក្តីថ្លែងការជាសាធារណៈស្តីអំពីសំដីគំរាមកំហែងការងាររបស់អ្នកការពារសិទ្ធិមនុស្ស ក៏ជាឧទាហរណ៏នៃការគំរាមកំហែងមួយទំរង់ផ្សេងទៀតដែរ ។ នៅឆ្នាំ ២000 នាយករដ្ឋមន្ត្រីបានប្រើភាសាគំរាមដោយផ្ទាល់ចំពោះអ្នកការពារសិទ្ធិមនុស្សជាច្រើនលើកច្រើនសារ ។ នៅខែ ធ្នូឆ្នាំ ២000 នាយករដ្ឋមន្ត្រីបានចោទប្រកាន់អង្គការសិទ្ធិមនុស្សមួយចំនួនថាបាន ”***លាក់បំពួនភេរវជនអោយជ្រកក្រោមផ្លាកសិទ្ធិមនុស្ស*** ” ហើយក្រោយពីមានការគំរាមនោះមកក៏មាន ការគំរាមចាប់អ្នកការពារសិទ្ធិមនុស្សដាក់ខ្នោះ ”***ដោយមិនបានគិតថា អ្នកនោះជាអ្នកការពារសិទ្ធិមនុស្សឡើយ*** ” ហើយការគំរាមដាក់ពន្ធនាគារដល់អ្នកការពារសិទ្ធិមនុស្ស ” ***ប្រសិនបើមានជាប់ពាក់ព័ន្ធជននោះ នឹងត្រូវចាប់ខ្លួន*** ” ភាសាគំរាមកំហែងដែលចេញមកពីមន្ត្រីកំពូលនៃរដ្ឋាភិបាលនៅក្នុងប្រទេសបានបង្កើតអោយមានការគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្ស ព្រមទាំងបន្តអោយមានភាពគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់អ្នកទាំងនោះតទៅទៀតផង ។

## ការបង្ករបួសស្នាម និងឃាតកម្ម

ការវាយដំលើរាងកាយក៏នៅតែជាទំរង់មួយដែលត្រូវបានប្រើប្រាស់ក្នុងអកប្បកិរិយាគំរាមកំហែងជារៀងរហូតមក ។ នៅឆ្នាំ ១៩៩៨ បុគ្គលិកឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាម្នាក់ត្រូវបានជនស្លៀកពាក់ស៊ីវិលម្នាក់វាយដំយ៉ាងដំណំ នៅខណៈដែលបុគ្គលិករូបនោះកំពុងឃ្លាំមើលព្រឹត្តិការបាតុកម្មមួយ ។ ពេលថ្មីៗនេះទៀតមន្ត្រីជាន់ខ្ពស់នៃទីភ្នាក់ងារត្រួតពិនិត្យព្រៃឈើឯករាជ្យមួយឈ្មោះ ***គ្លូបលវីតណេស*** ក៏ត្រូវបានជនមិនស្គាល់មុខវាយដំ និងទាត់ធាក់អោយដួលទៅ នឹងដីនៅក្បែរការិយាល័យរបស់គាត់ ។ ក្រោយពីករណីបង្ករបួសស្នាមនេះកើតឡើងមានលិខិតសារមួយដែលផ្ញើតាមប្រព័ន្ធអ៊ីមេលដែលសរសេរតែពាក្យគំរាមមួយម៉ាត់ដែលមានន័យថា ” ***ឈប់*** ”។ ការវាយដំនេះត្រូវបានគេជឿជាក់ថាជាអំពើមួយដែលជាប់ទាក់ទិនទៅនឹងរបាយការណ៏របស់អង្គការគ្លូបលវីតណេស ដែលសរសេរអំពីបទល្មើសនៃការកាប់បំផ្លាញព្រៃឈើយ៉ាងអនាធិបតេយ្យ ដែលមានមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលជាប់ទាក់ទិននៅក្នុងរឿងនោះ ។ នៅក្នុងឆ្នាំជាមួយគ្នានោះដែរក៏មានសកម្មជនសិទ្ធិមនុស្សអាដហុកម្នាក់នៅខេត្តកណ្តាល ត្រូវបានគេលបលួចតាមធ្វើឃាតផងដែរ ។ សកម្មជនរូបនោះត្រូវបានធ្វើឃាតក្នុងខណៈដែលគាត់កំពុងធ្វើជាតំណាងអោយប្រជាពលរដ្ឋចំនួន ១៤ គ្រួសារដែលត្រូវគេបណ្តេញចេញពីផ្ទះសម្បែងនឹងដីធ្លីរបស់ពួកគេ ។ ពាក់ព័ន្ធនឹងករណីនោះគេបានចាប់ជនល្មើសម្នាក់ ហើយក្រោយមកក៏ត្រូវបានតុលាការដោះលែងវិញនៅឆ្នាំ១៩៩៩ ។ បុគ្គលិកសិទ្ធិមនុស្សបានអះអាងថា ព្រោះតែមានអំពើ

ពុករលួយនៅក្នុងជួរមន្ត្រីកងទ័ព និងនគរបាលទើបបណ្តាលអោយមានការរារាំងយ៉ាងខ្លាំងចំពោះការស៊ើបអង្កេតអោយបានហ្មត់ចត់ និងមិនលំអៀងចំពោះករណីរំលោភសិទ្ធិមនុស្សទាំងឡាយ ។

## ការគំរាមកំហែងចាប់ និងឃុំខ្លួនខុសច្បាប់

ការចាប់ចង និងឃុំខ្លួនខុសច្បាប់តែងតែកើតមានជាទូទៅនៅកម្ពុជា ហើយបុគ្គលិកការពារសិទ្ធិមនុស្សក៏មិនទាន់ភ្លេចនៅក្នុងរឿងនេះនៅឡើយទេ ។ នៅឆ្នាំ ១៩៩៨ មានបុគ្គលិកអង្គការលីកាដូពីរនាក់ត្រូវបានចាប់ដាក់ពន្ធនាគារអស់រយៈពេលមួយខែក្រោយពេលដែលបុគ្គលិក ទាំងពីររូបនោះបានឃ្លាំមើលព្រឹត្តិការណ៍បាតុកម្មមួយនៅក្នុងទីក្រុងព្រះសីហនុដែលធ្វើឡើងប្រឆាំងទៅនឹងនាំចូលកាកសំណល់ដែលសារធាតុជាតិគីមីពុល ។ នៅក្នុងឆ្នាំ ១៩៩៩ បុគ្គលិកលីកាដូ និងបុគ្គលិកអាដហុកបានរត់គេចពីការប៉ុនប៉ងចាប់ខ្លួនយ៉ាងប្រផិតប្រផើយ ក្រោយពេលបុគ្គលិកទាំងនោះបានជួយដល់ជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនស្សនៅខេត្តកោះកុង ។ មានឧទាហរណ៏ស្រដៀងគ្នានេះដែរ បុគ្គលិកលីកាដូដែលបានជួយកម្មកររោងចក្រកាត់ដេរដែលត្រូវបានគេជួញដូរមកពីប្រទេសវៀតណាមក៏ត្រូវបានរងការគំរាមចាប់ចងផងដែរកាលពីខែមិនាឆ្នាំ ២000 កន្លងទៅនេះ ក្នុងនោះមានបុគ្គលិកម្នាក់ត្រូវបានគេចាប់ឃាត់ខ្លួននិងដោះលែងនៅពេលក្រោយមក ។ កាលពីខែធ្នូ ឆ្នាំ២00១ បុគ្គលិកសមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោមម្នាក់នៅខេត្តកំពង់ធំ ត្រូវបានចាប់ឃុំខ្លួនបណ្តោះអាសន្នព្រមទាំងត្រូវបានគេគំរាមថានឹងចាត់វិធានការតាមច្បាប់ដោយសារតែបុគ្គលិករូបនោះបានធ្វើការស៊ើបអង្កេតករណីបំផ្លិចបំផ្លាញឧបករណ៏នេសាទ ។ តាមរបាយការណ៏មួយបានអោយដឹងថា មានករណីធ្វើទារុណ្ណកម្មនៅមន្ទីរឃុំឃាំងរបស់នគរបាលស្ថិតក្នុងតួលេខមួយយ៉ាងខ្ពស់ដែលគួរអោយព្រួយបារម្ភណ៏ និងស្ថិតក្នុងស្ថានភាពដ៏យ៉ាប់យ៉ឺននៅក្នុងពន្ធនាគារកម្ពុជាព្រមទាំងការអនុវត្តន៏ការឃុំខ្លួនលើសនីតិវិធី ៦ ខែ ជាទូទៅគឺជារយៈពេលមួយកំណត់ឡើងដោយច្បាប់របស់កម្ពុជា ការគំរាមកំហែងចាប់ចងអាចក្លាយទៅជាការឃុំឃាំងមួយដែលមិនអាចកំណត់រយៈពេលបានក្នុងស្ថានភាពពន្ធនាគារដ៏គ្រោះថ្នាក់បែបនេះ [៧] ។

---

[7] តាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវលើសពី ៤ខែទេ។ តាមច្បាប់ព្រហ្ម ទណ្ឌអន្តរកាលក្នុងមាត្រា ១៤ បានចែងថា ការឃុំខ្លួនរយៈពេល ៦ ខែ គឺអនុញ្ញាតអោយធ្វើឡើងតែករណីណាពិ សេស១តែប៉ុណ្ណោះ។ ប៉ុន្តែតាមអ្នកស៊ើបអង្កេតរបស់អង្គការលីកាដូបានរកឃើញថាអាជ្ញាធរពុំបានគោរពទៅតាមរយៈពេលដែលបានកំណត់នេះទេ ។ ចំពោះពតិមានបន្ថែមស្តីអំពីពន្ធនាគារកម្ពុជា សូមអានរបាយការណ៏របស់ លីកាដូដែលមានចំណងជើងថា " សិទ្ធិមនុស្ស និង ពន្ធនាគារកម្ពុជាៈ ស្តីអំពីស្ថានភាពពន្ធនាគារ ឆ្នាំ ២00១ " និង របាយការណ៏មួយទៀត ដែលមានចំណងជើងថា " សិទ្ធិមនុស្ស និង ពន្ធនាគារកម្ពុជាៈស្តីអំពីស្ថានភាព សុខភាពនៅក្នុងពន្ធនាគារ ឆ្នាំ ២00១ " ។ របាយការណ៏ទាំងពីរនេះបានចេញផ្សាយរួចហើយនៅឆ្នាំ ២00២ ។

## ការគំរាមកំហែងចាត់វិធានការណ៍ច្បាប់តាមអំពើចិត្ត និងអាកប្បកិរិយាច្រងេងច្រងាង

អង្គកាលីកាដូ និងអង្គការសិទ្ធិមនុស្សផ្សេងៗទៀតដែលធ្វើការត្រួតពិនិត្យមើលការរំលោភសិទ្ធិមនុស្សមានការខ្វាយខ្វល់យ៉ាងខ្លាំងអំពីការចាត់វិធានការណ៍ច្បាប់តាមអំពើចិត្ត ដែលជាមធ្យោបាយមួយសំរាប់គំរាមកំហែងដល់ការងារសិទ្ធិមនុស្ស ។ ការចាត់វិធានការណ៍ច្បាប់តាមតែអំពើចិត្តនេះ គឺជាការគំរាមមួយដែលមានភាពទូលំទូលាយជាងការគំរាមចាប់ចងនិងឃុំឃាំងខុសច្បាប់ ដោយវាអាចហ៊ុំព័ទ្ធជុំវិញបញ្ហាដ៏ទៃទៀតរួមទាំងច្បាប់ព្រហ្មទណ្ឌរហូតដល់ច្បាប់រដ្ឋបាល។ ឧទាហរណ៍ការគំរាមកំហែងមួយផ្សេងតាមបែបរូបភាពអហឹង្សា ប៉ុន្តែផ្តល់ភាពគ្រោះថ្នាក់ដូចគ្នា នោះគឺជាការគំរាមកំហែងតាមផ្លូវច្បាប់ប្រឆាំងនឹងនាយកស្តីទីអង្គការលីកាដូកាលកាលពីឆ្នាំ ២០០០-២០០១ ។ កាលនោះអង្គការលីកាដូបានរួមសហការជាមួយនគរបាលធ្វើការស៊ើបអង្កេតករណីរំលោភរាងកាយលើកុមារ ហើយនៅពេលនោះគេបានស៊ើបអង្កេតរកឃើញកុមារីម្នាក់អាយុ ៧ឆ្នាំ បានរងការរំលោភរាងកាយយ៉ាងធ្ងន់ធ្ងរ ។ នគរបាលមូលដ្ឋានបានសំរេចចិត្តយកកុមាររងគ្រោះនោះចេញពីផ្ទះម្តាយចិញ្ចឹមដើម្បីរក្សាសុវត្ថិភាព ហើយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុញ្ញាតអោយអង្គការផ្តល់ជំនួយសង្គ្រោះជាបន្ទាន់ព្រមទាំង រកជំរកជ្រកនៅសំរាប់កុមារីនោះផងដែរ ។ ក្រោយមកទៀតតុលាការក៏បានអនុញ្ញាតអោយលីកាដូថែរក្សាកុមារីនោះបណ្តោះអាសន្នតាមផ្លូវច្បាប់ ។ ដើម្បីជាការសងសឹកទៅនឹងពាក្យបណ្តឹងរបស់អង្គការក្រៅរដ្ឋាភិបាលចំពោះករណីរំលោភលើរាងកាយកុមារ ឪពុកម្តាយចិញ្ចឹមរបស់កុមារីនោះបានប្តឹងបកមកវិញដោយចោទប្រកាន់ថា នាយកស្តីទីអង្គការលីកាដូបានចាប់ជំរិតនិងឃុំឃាំងកុមារីរងគ្រោះខុសច្បាប់ ។ តុលាការបានចោទប្រកាន់ម្តាយចិញ្ចឹមពីបទបង្ករបួសស្នាម (ដែលក្រោយមកត្រូវបានកាត់ ទោស)។ ទោះជាយ៉ាងនេះក្តី តុលាការនៅតែបន្តចោទប្រកាន់នាយកស្តីទីអង្គការលីកាដូពីបទឃុំឃាំងមនុស្សខុសច្បាប់ដដែល ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស ប្រចាំអាស៊ីបានរាយការណ៍ថា ***"ក្រុមអង្គការសិទ្ធិមនុស្សកម្ពុជា និងអន្តរជាតិបានសំដែងនូវការព្រួយបារម្ភចំពោះបណ្តឹងដោយពុំមានមូលដ្ឋានជាក់លាក់ ក្រៅពីធ្វើអោយមានការបំភិតបំភ័យដល់អង្គការលីកាដូច្រើនជាង*** "។ ក្រោយមកនាយកស្តីទីលីកាដូ បានដឹងថាចៅក្រមស៊ើបអង្កេតបានមានចេតនាចង់ចាប់នាងដាក់ពន្ធនាគារ ទីបំផុតការចោទប្រកាន់ពីបទឃុំឃាំងមនុស្សខុសច្បាប់នោះត្រូវបានតុលាការលើកលែងការចោទប្រកាន់ ក្រោយពេលមានការស៊ើបអង្កេតរបស់តុលាការរួចមក។ នៅថ្ងៃទី៦ ខែមិនា ឆ្នាំ២០០២ ជនល្មើសដែលបានធ្វើបាបលើរូបរាងកាយកុមារនោះបានប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ក្រោយពេលមានការវិនិច្ឆ័យរបស់តុលាក្រុងរួចជនល្មើសនៅតែបន្តប្តឹងនាយកស្តីទីដដែលរហូតមកដល់សព្វថ្ងៃកំពុងតែរង់ចាំស្តាប់លទ្ធផលចុងក្រោយនៃបណ្តឹងនេះនៅឡើយ។ ថ្មីៗនេះថ្នាក់ដឹកនាំអង្គការសិទ្ធិកម្ពុជាជាច្រើនបានសំដែងនូវការព្រួយបារម្ភយ៉ាង ខ្លាំងចំពោះការចាត់វិធានការណ៍

ច្បាប់ទាំងបំពាន ដែលជាមធ្យោបាយដើម្បីឃុំឃាំងអ្នកការពារសិទ្ធិមនុស្ស និងធ្វើអោយការងាររបស់គេមានភាពអន់ថយផងដែរ ។ ទង្វើបែបនេះគឺជាការប្តូរយុទ្ធសាស្រ្ត បំភិតបំភ័យពីការគំរាមកំហែងលើរូបរាងកាយទៅជាការគំរាមកំហែងតាមផ្លូវច្បាប់វិញ ហេតុនេះតំរូវអោយអង្គការក្រៅរដ្ឋាភិបាលនានា និងបណ្តាញគាំទ្រការងាររបស់អង្គការទាំងនោះត្រូវមានយុទ្ធសាស្រ្តរួមគ្នារកដោះស្រាយផ្សេងៗចំពោះបញ្ហានេះ ។

## ការប៉ះពាល់ដោយការគំរាមកំហែងទៅលើការងារសិទ្ធិមនុស្សនៅកម្ពុជា

ឥទ្ធិពលនៃការគំរាមកំហែងដែលកើតមានឡើងមកលើសុខមាលភាពខាងរូបរាងកាយ ខាងផ្លូវចិត្តនិងខាងផ្លូវច្បាប់របស់អ្នកការពារសិទ្ធិមនុស្សអាចធ្វើអោយអន់ថយដល់ការងារផ្នែកនេះផង ។អ្នកការពារសិទ្ធិមនុស្សអាចមានការរុញរាក្នុងការចូលទៅក្នុងតំបន់ខ្លះ ពួកគេអាចមានការស្ទាក់ស្ទើរក្នុងការស៊ើបអង្កេតករណីមួយចំនួន ឬពួកគេអាចបោះបង់ចោលការបន្តការស៊ើបអង្កេតដល់ករណីទាំងនោះ ។ ការស្ទាក់ស្ទើរចំពោះការបោះបង់ចោលការស៊ើបអង្កេតនេះអាចពុំមែនតែករណីធំៗ ដូចជាករណីពាក់ព័ន្ធការរំលោភសិទ្ធិខាងនយោបាយប៉ុណ្ណោះទេ ប៉ុន្តែអាចជាករណីមិនមែនពាក់ព័ន្ធរឿងនយោបាយក៏មានដែរ ។ ឧទាហរណ៏ករណីដែលគេប្តឹងបកមកលីកាដូវិញនៅឆ្នាំ២០០១ នោះអាចមានឥទ្ធិពលប៉ះពាល់ដល់អង្គការមួយចំនួន ដែលរួញរាមិនហ៊ានធ្វើអន្តរាគមន៏លើរណីរំលោភសិទ្ធិកុមារ ឬរួញរាក្នុងការផ្តល់ជំរកស្នាក់នៅដើម្បីសង្គ្រោះដល់កុមាររងគ្រោះទាំងឡាយទៀតផង [8] ។

ការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សបានស្ថិតនៅក្នុងកំរិតមួយយ៉ាងខ្ពស់ ជាពិសេសប្រសិនបើភ្នាក់ងាររដ្ឋាភិបាលជាអ្នកប្រព្រឹត្តិ ឬបណ្តាលអោយបញ្ហាការគំរាមកំហែងកើតមានឡើងទង្វើនេះបណ្តាលអោយក្រុមសិទ្ធិមនុស្ស និងភ្នាក់ងារអាជ្ញាធរបាត់ទំនុកចិត្តរវាងគ្នាទៅវិញទៅមក ហើយអាចឈានទៅរកការចុះថយនូវសក្តានុពលចំពោះពួកគេក្នុងកិច្ចសហការការងារដើម្បីអោយសំរេចគោលដៅរួម ។ ប៉ុន្តែក៏ នៅមានឱកាសដើម្បីកែលំអផងដែរ -កន្លងមកអង្គការក្រៅរដ្ឋាភិបាលកម្ពុជាមានមោទនៈភាពយ៉ាងក្រៃលែងចំពោះទំនាក់ទំនងសហប្រតិបត្តិការ ដែលពួកគេបានពិគ្រោះពិភាក្សាជាមួយអាជ្ញាធរដែនដីមួយចំនួន ដែលមួយផ្នែកបានជួយដល់ការបង្ហាញនូវជោគជ័យរបស់អង្គការក្រៅរដ្ឋាភិបាលសំរេចបាន ឧទាហរណ៏ដូចជា ការត្រួតពិនិត្យពន្ធនាគារ និងការបើកវគ្គបណ្តុះបណ្តាលដល់នគរបាលជាដើម [9] ។ ដោយការប្រើវិធីសាស្រ្តសហប្រតិបត្តិការ ជារឿយៗអង្គការក្រៅរដ្ឋាភិបាលអាចកែលំអលទ្ធភាពក្នុងការ

---

[8] ចំពោះពត៌មានលំអិតបន្ថែម សូមអានឧបសម្ព័ន្ធ ។

[9] សារា ខុម ទំព័រ ១១។

ផ្លាស់ប្តូរតំរិយាបទ ឬលទ្ធផលនៅក្នុងផ្នែកបុគ្គលិករដ្ឋ ។ ប៉ុន្តែនៅពេលណាមានការប្រឈមមុខនឹងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរមកលើអ្នកការពារសិទ្ធិមនុស្សកិច្ចសហប្រតិបត្តិការនេះត្រូវបានបាត់បង់ទៅវិញ ។

## ការប៉ះពាល់មកលើសង្គមស៊ីវិល

ការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សបានជះឥទ្ធិពលយាយីមកលើសង្គមស៊ីវិលផងដែរ ។ វាអាចធ្វើអោយជនរងគ្រោះដោយហេតុផលការរំលោភសិទ្ធិមនុស្សរួញរាក្នុងការអនុវត្តន៏សិទ្ធិរបស់ពួកគេដើម្បីស្វែងរកយុត្តិធម៌រួញរាក្នុងការប្តឹងមកអង្គការសិទ្ធិមនុស្សព្រមទាំងអង្គការផ្សេងៗ និងរួញរាក្នុងការប្តឹងជនល្មើសទៅតុលាការ ។ ចន្លោះប្រហោងកង្វះខាតអនាគតិនៅក្នុងប្រព័ន្ធតុលាការក៏ជាការរួមចំណែកក្នុងការភ័យខ្លាចនេះផងដែរដូចជាការគំរាមកំហែង និងការប៉ុនប៉ងចាប់ឃុំឃាំងដាក់ក្នុងពន្ធនាគារកម្ពុជាមួយជាដើម ។ ល្បិចបន្លាចនិងការបំភិតបំភ័យដល់អ្នកការពារសិទ្ធិមនុស្ស ក៏ជាមូលហេតុមួយដែលធ្វើអោយសាធារណៈជនទូទៅមានការស្ទាក់ស្ទើរក្នុងការបញ្ចេញមតិ ការរិះគន់គោលនយោបាយ ឬសកម្មភាពរបស់រដ្ឋាភិបាល ឬការចូលរួមជំទាស់លើកិច្ចការនយោបាយផងដែរ ។ ការគំរាមទាំងនេះបានធ្វើអោយមានការចុះអន់ថយនូវសេរីភាពនៃការចូលរួមបង្កើតសមាគមន៏ សេរីភាពនៃការចូលរួមប្រជុំ និងសេរីភាពនៃការបញ្ចេញមតិជាដើម ។ ប៉ុន្តែទង្វើទាំងអស់នេះប្រហែលជាមិនបានធ្វើអោយយើងមើលឃើញច្បាស់លាស់តាមវិធីសាស្ត្រមួយចំនួននោះទេ តែវាជាវិធីបន្លាចយ៉ាងអាថ៌កំបាំងដែលបង្កើតអោយមានភាពមន្ទិលសង្ស័យ និងភាពពុំមានការសន្ទោសប្រណីមកលើសកម្មភាពរបស់ប្រជារាស្ត្រ ។ ជារួមការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្ស វាជាការរំលោភមកលើសិទ្ធិជាមូលដ្ឋានរបស់ប្រជារាស្ត្រកម្ពុជាទូទៅផងដែរ ដោយបានបំបិទសេរីភាពនៃការបញ្ចេញមតិ និងការចូលរួមក្នុងសកម្មភាពប្រជាធិបតេយ្យ ។

## ការកែលំអយន្តការដើម្បីការពារ

ក្រៅពីការចាត់វិធានការណ៍ការពារសន្តិសុខផ្ទាល់ខ្លួនជាមូលដ្ឋាន ដើម្បីទប់ទល់នឹងការគំរាមកំហែងចំពោះបុគ្គលិកសិទ្ធិមនុស្ស គេក៏ត្រូវបង្កើតអោយមានយន្តការការពារដ៏មានប្រសិទ្ធិភាពមួយថែមទៀតផងដែរ ។ ពីព្រោះការគំរាមកំហែងភាគច្រើនផ្តើមចេញពីមន្ត្រីក្នុងជួររដ្ឋាភិបាល ហេតុដូច្នេះការបញ្ចុះបញ្ចូលស្ថាប័នរដ្ឋាភិបាលអោយចូលរួមក្នុងការទប់ស្កាត់លំដាប់ថ្នាក់ជាតិដ៏ធំមួយនោះ គឺពុំទាន់មានប្រសិទ្ធិភាពគ្រប់គ្រាន់នៅឡើយទេ ។ ដូចដែលអ្នកការពារសិទ្ធិមនុស្សមិនបញ្ចេញម្នាក់បានសរសេរថា "

***នៅកម្ពុជាអ្នកត្រូវការពារខ្លួនដោយខ្លួនឯង ពី ព្រោះគ្មាននរណាការពារអ្នកទេ*** " ហើយ " ***ជាការពិតណាស់គឺនគរបាលដែលយើងត្រូវតែខ្លាចគ្រប់ពេលវេលា*** " ដោយសារតែហេតុផលនេះទើប លីកាដូសូមទាមទារយ៉ាងទទូចអោយមានការលើកកំពស់នូវបណ្តាញថ្នាក់តំបន់និងអន្តរជាតិដើម្បីធ្វើការបញ្ចុះបញ្ចូលបញ្ហាការ ពារបុគ្គលិកសិទ្ធិមនុស្សអោយមានប្រសិទ្ធិភាពឡើង ។ មកទល់ពេលនេះយើងឃើញថា មានការគាំទ្រយ៉ាងខ្លាំងពីសំណាក់បណ្តាញសិទ្ធិមនុស្សប្រចាំតំបន់ និងអន្តរជាតិ ប៉ុន្តែក៏នៅមានឱកាសសំរាប់កែលំអ និងពង្រីកថែមទៀតដែរ ។ អង្គការលីកាដូនៅបានពិចារណាលើការបង្កើតបណ្តាញប្រព្រឹត្តិកម្មគឺជាអាទិភាពបន្ទាន់លំដាប់ថ្នាក់តំបន់មួយ ។

ភារៈកិច្ចអង្គការសិទ្ធិមនុស្សការពារចំពោះបុគ្គលិករបស់ខ្លួនជាភារៈកិច្ចមួយដែលត្រូវលើកយកមកពិចារណា ។ ការបង្កើតអោយមានមូលនិធិសង្គ្រោះបន្ទាន់នៅក្នុងអង្គការនីមួយៗ ឬមូលនិធិសហសង្គ្រោះក្នុងចំណោមអង្គការទាំងឡាយ គឺជាយន្តការការពារមួយដែលត្រូវលើកយកមកពិភាក្សាក្នុងវេទិការអង្គការក្រៅរដ្ឋាភិបាល ។ មូលនិធិសង្គ្រោះបែបនេះអាចធ្វើអោយបុគ្គលិកសិទ្ធិមនុស្សដែលជួបប្រទះគ្រោះថ្នាក់ត្រូវបានសង្គ្រោះភ្លាមៗអោយទាន់ពេលវេលា ។ ប៉ុន្តែលីកាដូ និងអង្គការសិទ្ធិមនុស្សមួយចំនួនទៀតបានចាត់ទុកការសង្គ្រោះបន្ទាន់នេះជាជំរើសចុងក្រោយបង្អស់ ពីព្រោះការជំលៀសបុគ្គលិកចេញគឺជាការផ្តល់សញ្ញាទៅជនល្មើសដែលប្រព្រឹត្តិអំពើនោះ ថាយុទ្ធសាស្រ្តបំភិតបំភ័យរបស់ពួកគេបានទទួលជោគជ័យទៅវិញ ។

## បទដ្ឋាននិត្យានុកូលកម្ពុជា និងអន្តរជាតិដែលទាក់ទងគ្នា

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការសន្យាថ្នាក់ជាតិ និងអន្តរជាតិក្នុងការការពារបុគ្គលិកសិទ្ធិមនុស្ស ។ នៅក្នុងកិច្ចព្រមព្រៀងសន្តិភាព ក្រុងប៉ារីសឆ្នាំ១៩៩១ បានផ្តល់កិច្ចការពារផ្នែកច្បាប់ដល់បុគ្គលិកសិទ្ធិមនុស្សផងដែរ ដោយរួមមានទាំងសេរីភាពក្នុងការចូលរួមបង្កើតសមាគម សេរីភាពចូលរួមប្រជុំ និងសេរីភាពនៃការបញ្ចេញមតិ ។ នៅឆ្នាំ ១៩៩២ ប្រទេសកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើច្បាប់សិទ្ធិមនុស្សអន្តរជាតិដ៏សំខាន់មួយចំនួន រួមមានទាំងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងកត្តិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច វប្បធម៌ និងសង្គមផងដែរ[១០] ។ មាត្រា ២២

[10] រាជរដ្ឋាភិបាលកម្ពុជា ក៏បានផ្តល់សច្ចាប័នបន្ថែមទៀតលើច្បាប់សិទ្ធិមនុស្សអន្តរជាតិៈដូចជា អនុសញ្ញាអន្តរ ជាតិស្តីពីការលប់បំបាត់រាល់ទំរង់នៃការប្រកាន់ពូជសាសន៍-អនុសញ្ញាស្តីពីការលប់បំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ —អនុសញ្ញាស្តីពីសិទ្ធិកុមារ -អនុសញ្ញាប្រឆាំងទារុណ្ឌកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តិទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំអោយបាត់បង់តំលៃជាមនុស្ស និងអនុសញ្ញាដែលទាក់ទិនទៅនឹងឋានៈនៃជនភៀសខ្លួនជាដើម ។

នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយបានចែងថា ៈ ***មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការចូលជាសមាគមជាមួយនឹងអ្នកដទៃ***[១១] ។ សេរីភាពក្នុងការចូលជាសមាគមនេះក៏ត្រូវបានដាក់បញ្ចូលផងដែរនៅក្នុង ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ។ មាត្រា ៤២ នៃច្បាប់នេះបានចែងថា ៈ ***ប្រជាជនខ្មែរគ្រប់រូបមានសិទ្ធិក្នុងការ បង្កើតសមាគម និងគណបក្ស នយោបាយ***[១២] ។

អង្គការសិទ្ធិមនុស្សមានភាពស្របច្បាប់ និងប្រតិបត្តិការអស់រយៈពេលជាងមួយទសវត្សកន្លងមកហើយក្នុងប្រទេសកម្ពុជា ។ ប្រការដែលពុំមាននូវការបន្តចំពោះកិច្ចការពារ និងការលើកកំពស់ជាពិសេសនោះហើយ ទើបការបដិសន្ធិការងារសិទ្ធិមនុស្សមានសារៈសំខាន់ជាជំហានរួមចំណែកមួយក្នុងការស្តារសង្គមកម្ពុជាឡើងវិញ និងការវិវឌ្ឍន៍ទៅរកកិច្ចការពារជាយថាហេតុរបស់ខ្លួនដូចមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជានោះ តែទោះជាយ៉ាងណាវាក៏អាចនៅតែងាយរងទទួលនូវគ្រោះថ្នាក់ជាដដែល ។ ការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សមិនត្រឹមតែរំលោភមកលើសេរីភាពនៃការចូលរួមក្នុងសមាគម និងសេរីភាពនៃការបញ្ចេញមតិរបស់អង្គការតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរំលោភលើសិទ្ធិជាទូទៅដល់ជនរងគ្រោះដែលស្វែងរកការជួយគាំពារដំណោះស្រាយបញ្ហាទុក្ខលំបាករបស់គេផងដែរ ។ ជនល្មើសដែលមានអំណាចអាចគំរាម ដល់អ្នកការពារសិទ្ធិមនុស្សនៅពេលបំពេញការងារស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្សណាមួយ ។ ការគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្ស ក៏ដូចជាការគំរាមដល់ជនរងគ្រោះ និងការគំរាមដល់ការលើកកំពស់សិទ្ធិមនុស្សជាទូទៅផងដែរ ។ ចំពោះហេតុផលនេះសូមទាមទារអោយរាជរដ្ឋាភិបាលកម្ពុជាគាំទ្រនូវសេចក្តីប្រកាសនៃមហាសន្និបាទអង្គការសហប្រជាជាតិស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការបំរើសង្គមដើម្បីលើកកំពស់ និងការពារសិទ្ធិមនុស្សព្រមទាំងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល[១៣] ។ ជាពិសេសរាជរដ្ឋាភិបាលគួរប្រកាន់ខ្ជាប់តាមមាត្រា ៩ (១) និង (៣) ដែលបានចែងថាៈ

(១) ***-ក្នុងការអនុវត្តន៍សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន រួមទាំងការលើកកំពស់និងកិច្ចការពារសិទ្ធិមនុស្ស ដូចដែលមាននៅក្នុងសេចក្តីប្រកាសនាបច្ចុប្បន្នមនុស្សគ្រប់រូបមានសិទ្ធិជាបុគ្គលនិងចូលរួមជាមួយអ្នកដទៃ ដើម្បីទទួលបានផលប្រយោជន៍យ៉ាងមានប្រសិទ្ធិភាព និងដើម្បីទទួលកិច្ចការពារក្នុងព្រឹត្តិការណ៍នៃការរំលោភលើសិទ្ធិទាំងនោះ ។***

---

[11] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[12] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣

[13] សេចក្តីប្រកាសនៃមហាសន្និបាតអង្គការសហប្រជាជាតិស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងធាតុនៃ សង្គមដើម្បីលើកកំពស់ នឹងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលបានទទួលស្គាល់ជាសកល ។

*(៣) - ជាទីបញ្ចប់ មនុស្សគ្រប់រូបមានសិទ្ធិជាលក្ខណៈបុគ្គល និងរួមជាមួយអ្នកដទៃដូចជាៈ ក- ដើម្បីតវ៉ាប្រឆាំងគោលនយោបាយ និងសកម្មភាពរបស់បុគ្គល មន្ត្រី និងអង្គការរដ្ឋ ចំពោះអំពើរំលោភសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដោយការធ្វើញត្តិ ឬមធ្យោបាយសមរម្យណាផ្សេងទៀត ទៅតុលាការ រដ្ឋបាល ឬអាជ្ញាធរនីតិបញ្ញត្តិដែលមានសមត្ថកិច្ចក្នុងប្រទេស ឬអាជ្ញាមានសមត្ថកិច្ចណាមួយដែលត្រូវបានផ្តល់ដោយប្រព័ន្ធច្បាប់របស់រដ្ឋ ដែលអាចធ្វើការសំរេចសេចក្តីលើបណ្តឹងដោយមិនពន្យាពេល*[១៤]។

## អនុសាសន៏

អង្គការលីកាដូនៅតែមានការខ្វាយខ្វល់យ៉ាងខ្លាំងអំពីការវាយប្រហារដោយពាក្យសំដី ការបង្ករអោយមានរបួសស្នាម និងការគំរាមតាមផ្លូវច្បាប់តាមអំពើចិត្តមកលើអ្នកការពារសិទ្ធិមនុស្ស ។ អាស្រ័យដោយការគំរាមកំហែងនេះកាន់តែមានស្ថានភាពធ្ងន់ធ្ងរ អង្គការលីកាដូ សូមទាមទារអោយមានវិធានការដូចខាងក្រោម :

### រាជរដ្ឋាភិបាលកម្ពុជា

- រដ្ឋាភិបាលត្រូវតែបន្តទទួលស្គាល់អង្គការសិទ្ធិមនុស្សជាអង្គការត្រឹមត្រូវតាមច្បាប់ និងទទួលស្គាល់សារៈសំខាន់នៃការងាររបស់អង្គការទាំងនោះក្នុងការអភិវឌ្ឍន៏សង្គមស៊ីវិលនៅកម្ពុជា ។ កត្តានេះអាចរួមមានការលប់បំបាត់នូវឧបស័គ្គទាំងឡាយណាដែលរារាំងដល់ការប្រតិបត្តិការការងាររបស់អង្គការសិទ្ធិមនុស្សទាំងឡាយ ដូចជាត្រូវធ្វើអោយដំណើរការស៊ើបអង្កេតមានតម្លាភាពជាងមុនផងដែរ ។
- រាជរដ្ឋាភិបាលកម្ពុជាត្រូវចាត់ការជាជំហ៊ាន១ជាបន្ទាន់ ដើម្បីផ្តន្ទាទោសជនល្មើសដែលបានប្រព្រឹត្តិអំពើហឹង្សា បំភិតបំភ័យដល់បុគ្គលិកសិទ្ធិមនុស្ស។
- រាជរដ្ឋាភិបាលត្រូវតែប្តេជ្ញាអនុវត្តន៏ច្បាប់ក្នុងប្រទេសនិងច្បាប់អន្តរជាតិរបស់ខ្លួនដែលបានសន្យា និងហាមឃាត់មិនអោយមានការបំភិតបំភ័យ ការគំរាមកំហែងដើម្បីទប់ស្កាត់ ឬបំភិតបំភ័យការងាររបស់អ្នកការពារសិទ្ធិមនុស្ស ។

---

[14] Ibit., មាត្រា ៩ (១) និង (៣)

- អង្គការលីកាដូទាមទារយ៉ាងទទូចដល់រាជរដ្ឋាភិបាល ដើម្បីអោយមានការគាំទ្រដល់សេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គលក្រុម និងអង្គការបំរើសង្គមដើម្បីលើកកំពស់ នឹងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល ។ ជាពិសេសរាជរដ្ឋាបាលត្រូវតែប្រកាន់ខ្ជាប់នូវមាត្រា ៩ និងមាត្រា ១២ នៃសេចក្តីប្រ កាសនេះដែលផ្តល់សិទ្ធិដល់បុគ្គល និងអង្គការដើម្បីឃ្លាំមើល តវ៉ាប្រឆាំងនឹងសកម្មភាពរបស់រាជរដ្ឋាភិបាល ក៏ដូចជាសុំអោយរដ្ឋាភិបាលផ្តល់កិច្ចការពារដល់បុគ្គល និងអង្គការដែលរងការគំរាមកំហែងទាំងឡាយ ។

## រដ្ឋាភិបាលបរទេស និងទីភ្នាក់ងារផ្តល់ជំនួយនានា

- អង្គការលីកាដូបានចាត់ទុកការជួយយ៉ាងធំធេងពីសំណាក់រដ្ឋាភិបាលបរទេសស្ថានទូតនិងអង្គការផ្តល់ជំនួយទាំងឡាយ គឺជាកិច្ចការចាំបាច់និងមានសារៈសំខាន់បំផុតក្នុងការអភិវឌ្ឍន៍យន្តការការពារបុគ្គលិកសិទ្ធិមនុស្សនៅកម្ពុជា ។
- ក្នុងករណីមានចំណោតការខាងផ្លូវច្បាប់ដោយទទឹងទិស និងដោយតាមអំពើចិត្តមកលើបុគ្គលិកការពារសិទ្ធិមនុស្ស រដ្ឋាភិបាលបរទេស និងម្ចាស់ជំនួយទាំងឡាយគួរតែផ្តល់ពត៌មានដល់រាជរដ្ឋាភិបាលកម្ពុជាអំពីពត៌មាន ដែលខ្លួនបានដឹងទាក់ទិនទៅនឹងការប្រើប្រាស់មធ្យោបាយច្បាប់ ដើម្បីគំរាមបុគ្គលិកសិទ្ធិមនុស្សនោះ ។ ទង្វើនេះអាចជំរុញអោយរាជរដ្ឋាភិបាលលប់បំបាត់ចោលនូវឧបស័គ្គទាំងឡាយដែលរារាំងដល់ការងារសិទ្ធិមនុស្ស ឬម៉្យាងទៀតអាចជួយគាំទ្រដោយការផ្តល់នូវជំនួយផ្នែកច្បាប់ដល់បុគ្គលិកសិទ្ធិមនុស្សដែលកំពុងជួបប្រទះនូវបញ្ហានោះទៀតផង ។

## អង្គការសិទ្ធិមនុស្សកម្ពុជានានា

- អង្គការលីកាដូ សូមអញ្ជើញអង្គការសិទ្ធិមនុស្សកម្ពុជានានារួមពិភាក្សា និងជុំរុញសហប្រតិបត្តិការស្តីពីការបង្កើតយន្តការការពារ ទាំងរយៈខ្លី និងរយៈពេលវែង ។ កិច្ចការនេះរួមមានការមិនកំណត់នូវការតស៊ូមតិ និងកិច្ចការពារតាមផ្លូវច្បាប់ ការបង្កើតនូវមូលនិធិសង្គ្រោះបន្ទាន់និងនីតិវិធីដោះស្រាយ ព្រមទាំងការចូលរួមក្នុងបណ្តាញប្រព្រឹត្តិកម្មបន្ទាន់ថ្នាក់តំបន់ ។
- ការបង្កើតឡើងនូវបណ្តាញប្រព្រឹត្តិកម្មបន្ទាន់ថ្នាក់តំបន់នេះ គឺជាសំណើរដ៏យ៉ាងទទូចជាទីបំផុត ។ បណ្តាញបែបនេះ នឹងចាត់វិធានការជាបន្ទាន់ដើម្បីផ្សព្វផ្សាយនូវការគំរាមកំហែងដើម្បីទាក់

ទាញមតិអោយអាជ្ញាធរកម្ពុជាចាត់វិធានការចំពោះជនល្មើសអោយបានសមស្រប ក៏ដូចការចាត់វិធានការដើម្បីថែរក្សាការពារ និងជំលៀសបុគ្គលិកសិទ្ធិមនុស្សណាដែលកំពុងប្រឈមមុខនឹងបញ្ហាបែបនេះក្នុងករណីណាមួយដែលចាំបាច់ ។

- អ្នកការពារសិទ្ធិមនុស្ស នៅកម្ពុជាត្រូវតែខំប្រឹងប្រែងរួមដើម្បីប្រមូលចងក្រងឯកសាររាល់ការគំរាមកំហែងដល់សន្តិសុខវិជ្ជាជីវៈ និងផ្ទាល់ខ្លួនរបស់គេហើយធ្វើការទំនាក់ទំនងការគំរាមកំហែងទាំងនេះ ដើម្បីអោយមានកិច្ចការពារពិតតែមាំមួន នឹងប្រសើរឡើងដល់សង្គមស៊ីវិលកម្ពុជា ។
- អង្គការសិទ្ធិមនុស្សកម្ពុជានានាគួរតែប្រឹងប្រែង ដើម្បីអោយមានការជំរឿនដល់សេចក្តីប្រកាសនៃមហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការបំរើសង្គមដើម្បីលើកកំពស់ នឹងការពារសិទ្ធិមនុស្ស ព្រមទាំងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល ។

**ឈ្មោះអង្គការជាអក្សរកាត់ និង ឈ្មោះពេញរបស់អង្គការ**

| | |
|---|---|
| ADHOC | សមាគមកម្ពុជាដើម្បីសិទ្ធិមនុស្ស នឹងអភិវឌ្ឍន៍ |
| CDP | គំរោងការពារក្តីកម្ពុជា |
| CFF | អ្នកច្បាំងដើម្បីសេរីភាពកម្ពុជា |
| CHRAC | គណកម្មការប្រព្រឹត្តិកម្មសិទ្ធិមនុស្សកម្ពុជា |
| COHCHR | ឧត្តមស្នងការអង្គការហសប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា |
| CPP | គណបក្សប្រជាជនកម្ពុជា |
| FUNCINPEC | គណបក្សហ៊្វុនស៊ិនប៉ិច |
| KKKHRA | សមាគមសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម |
| KRC | មជ្ឈមណ្ឌលធនធានខ្មែរ |
| LICADHO | សម្ព័ន្ធខ្មែរជំរឿន នឹងការពារសិទ្ធិមនុស្ស ( លីកាដូ) |
| UNHCR | ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន |
| UNTAC | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា ( អ៊ុនតាក់) |

**របាយការណ៍ឧបសម្ព័ន្ធការគំរាមកំហែងមកលើ ឬការវាយប្រហារមកលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ក្នុងកំឡុងពេល៥ ឆ្នាំ ចាប់ពីឆ្នាំ ១៩៩៧ -២០០២**[១៥]

| ឆ្នាំ | ខែ | ព្រឹត្តិការណ៍ |
|---|---|---|
| ១៩៩៧ | សីហា | អ្នកស៊ើបអង្កេតនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (UNCOHCHR) ទទួលរងការបំភិត បំភ័យដោយមានការបាញ់កាំភ្លើងអាកា ៤៧ ពីលើក្បាលក្នុងខណៈដែលពួកគេកំពុងស៊ើបអង្កេតនៅរណ្តៅសាកសពមួយ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំអាស៊ីក៏បានរាយការផងដែរថា ក្រោយមកអ្នកស៊ើបអង្កេតទាំងនោះក៏បានឮតាមវិទ្យុទាក់ទងនូវសំលេងមន្ត្រីយោធារដ្ឋាភិបាលសួរយោបល់គ្នាថា តើត្រូវសំរេចសំលាប់អ្នកទាំងនោះដែរឬទេ ។ |
| ១៩៩៧ | តុលា | គណបក្សប្រជាជនដែលកាន់អំណាចបានបង្កើតគណៈកម្មការ ដើម្បីត្រួតពិនិត្យអង្គការក្រៅរដ្ឋាភិបាលដែលមានគោលដៅធ្វើការស៊ើបអង្កេតទៅលើអង្គការដែលបានជ្រើសរើសមួយចំនួនជាពិសេសអង្គការដែលមានគោលការណ៍ការងារបំរើសិទ្ធិមនុស្ស ។ |
| ១៩៩៨ | កុម្ភៈ | បុគ្គលិកអង្គការ ADHOC, VIGILANCE, LICADHO និង KRC ត្រូវបានទាហ៊ានមួយក្រុមតាម ក្នុងខណៈបុគ្គលិកទាំង នោះកំពុងស៊ើបអង្កេតករណីមួយក្នុងស្រុកត្បូងឃ្មុំ ខេត្តកំពង់ ចាម ។ |
| ១៩៩៨ | កុម្ភៈ | យោធាបានប្តឹងអង្គការ CHRAC ទៅតុលាការពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតរបស់អង្គការលើករណីគំរាមកំហែងទៅលើបុគ្គលិកសិទ្ធិមនុស្សម្នាក់នៅកំពង់ចាម ។ កងពលបានដាក់ពាក្យបណ្តឹងទៅតុលាការកំពូល និងរដ្ឋសភាដោយទាមទារអោយសងជំងឺចិត្តចំនួន ៧០.០០០ ដុល្លាអាមេរិក ដោយចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ។ |
| ១៩៩៨ | មេសា | បុគ្គលិកឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានរងរបួស ដោយករណីបង្ករបួសស្នាមដែលប្រព្រឹត្តិដោយកងកំលាំងសន្តិសុខរដ្ឋាភិបាលក្នុងខណៈដែលបុគ្គលិករូបនោះកំពុងឃ្លាំមើលសកម្មភាពបាតុកម្ម ។ បុគ្គលិករូបនោះត្រូវបានយកមកសំរាកព្យាបាលនៅមន្ទីរពេទ្យ ។ |
| ១៩៩៨ | កញ្ញា | មន្ត្រីសន្តិសុខរបស់រដ្ឋាភិបាលបានគំរាមរំខានដល់បុគ្គលិកសិទ្ធិមនុស្ស ទាំងអន្តរជាតិនិងជាតិក្នុងខណៈដែលធ្វើការឃ្លាំមើលបាតុកម្មក្រោយពេលបោះឆ្នោត ឬជួយអ្នករបួស ។ |

---

15 ប្រភពពតិមានទទួលបានពីៈ របាយការណ៍ទូទៅរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំអាស៊ី ១៩៩៧-២០០១- របាយការណ៍ប្រចាំឆ្នាំរបស់ ADHOC ឆ្នាំ ២០០១ និង ការសំភាសន៍ផ្ទាល់ជាមួយបុគ្គលិកសិទ្ធិមនុស្ស ។

១៩៩៨ ធ្នូ  បុគ្គលិកលីកាដូពីរនាក់ គឹម សែន និង មាស មីនា ត្រូវបានចាប់ខ្លួនចោទប្រកាន់ និងឃុំខ្លួនក្នុងពន្ធនាគារអស់រយៈពេលមួយ ខែក្រោយពីគេទាំងពីរបានធ្វើការឃ្លាំមើលបាតុកម្មប្រឆាំងនឹងការនាំចូលកាកសំណល់ដែលមានជាតិពុលនៅក្រុងព្រះសីហនុ ។

១៩៩៨ ធ្នូ  អ្នកសកម្មជនសិទ្ធិមនុស្សម្នាក់ឈ្មោះ ពួង តុង ត្រូវបានគេសំលាប់នៅខេត្តកណ្តាល។ អំពើឃាតកម្មនោះទំនងជាពាក់ព័ន្ធទៅ នឹងករណីទំនាស់ដីធ្លីដ៏យូរអង្វែងមួយដែលជនរងគ្រោះនិងប្រជាជនចំនួន ១៤ គ្រួសារទៀតជាកម្មករការដ្ឋានកិនថ្មដែលមានទំនាស់ជាមួយក្រុមហ៊ុន ។ ជនរងគ្រោះគឺជាតំណាងប្រជាជនទាំង១៤ គ្រួសារដែលពាក់ព័ន្ធក្នុងរឿងជំលោះដីធ្លីនោះក្នុងការប្តឹងផ្តល់ទៅតុលាការ ។

១៩៩៨ ធ្នូ  បុគ្គលិកឧត្តមស្នងការអង្គការសហប្រជាជាតិម្នាក់បានទទួលរងការវាយប្រហារដោយកងរាជអាវុធហត្ថ ចំនួន៤នាក់ ក្នុងខណៈ ដែលបុគ្គលិករូបនោះកំពុងជិះម៉ូតូនៅក្នុងទីក្រុងភ្នំពេញ ។ កងរាជអាវុធហត្ថបានគំរាមសំលាប់ជនរងគ្រោះ ក្រោយមកគេបានដាល់មុខគាត់ លួចយក ម៉ូតូរបស់គាត់ ចាប់គាត់ដាក់ក្នុងរថយន្ត របស់ពួកគេហើយបើកយកចេញទៅ ។ នៅក្នុងរថយន្តនោះ កងរាជអាវុធហត្ថបានដកហូតយកកាបូបទូរស័ព្ទ វិទ្យុទាក់ទង និងលុយកាក់ ព្រមទាំងសំភារៈផ្ទាល់ខ្លួនផ្សេងៗទៀត។ បុគ្គលិករូបនោះក៏បានលោតចេញពីរថយន្តហើយរត់សំដៅទៅរកសន្តិសុខសណ្ឋាគារនៅតាមផ្លូវធំមួយក្នុងទីក្រុង ។ ក្រោយមកបុគ្គលិករូបនោះក៏បានទទួលសំភារៈរបស់គាត់ទាំងអស់ត្រឡប់មកវិញ ក្រោយពីមានការចរចាររវាងឧត្តមស្នងការអង្គការសហប្រជាជាតិនឹងកងរាជអាវុធហត្ថ ។

១៩៩៩ មករា  តំណាងអង្គការសិទ្ធិមនុស្សកម្ពុជានៅក្នុងខេត្តចំនួន ៧ ត្រូវបានបំភិតបំភ័យដោយអាជ្ញាធររដ្ឋាភិបាល ហើយបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលម្នាក់ត្រូវបានគំរាមចាប់ខ្លួនក្នុងយុទ្ធនាការប្រមូលហត្ថលេខាពីប្រជា ជនកម្ពុជាដើម្បីស្នើសុំអោយអង្គការសហប្រជាជាតិបង្កើតនូវសាលាជំរះក្តីអន្តរជាតិដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមមួយចំនួន ។

១៩៩៩ កក្កដា  បុគ្គលិកអង្គការលីកាដូ និងអាដហុកនៅខេត្តកោះកុងត្រូវបានគំរាមរកចាប់ខ្លួនក្រោយពីជួយធ្វើអន្តរាគមន៍ករណីសិទ្ធិមនុស្សមួយ ។ ក្រោយមកឧត្តមស្នងការសហប្រជាជាតិនិងគណកម្មការប្រព្រឹត្តិកម្មសិទ្ធិមនុស្សក៏បានជួយធ្វើអន្តរាគមន៍បន្ថែមទៀត ។

១៩៩៩ កក្កដា  បុគ្គលិកអង្គការលីកាដូ ២ នាក់បានឡើងតុលាការក្រោយពីត្រូវបានចាប់ខ្លួននៅក្នុង

| | |
|---|---|
| | ឆ្នាំ១៩៩៨ ក្រោយពេលដែលគេទាំងពីរនាក់ បានឃ្លាំមើលសកម្មភាពធ្វើបាតុកម្មនៅទីក្រុងព្រះសីហនុ ។ ទោះបីជាបុគ្គលិកទាំងពីរនាក់នោះត្រូវបានលើកលែងការចោទប្រកាន់ក៏ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និងអ្នកសង្កេតការអន្តរជាតិបានលើកឡើងថា គេមិនគួរនឹងបើកសវាការទាល់តែសោះ ពីព្រោះពុំមានភស្តុតាងគ្រប់គ្រាន់ណាមួយ និងមានកំហុសឆ្គងខាងនីតិវិធីច្បាប់ទៀតផង ។ ករណីនេះដកស្រង់ពីរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំអាស៊ី ។ |
| ១៩៩៩ កញ្ញា | យោធាកងពលលេខ ២ បានផ្ញើលិខិតគំរាមជាផ្លូវការមកការិយាល័យឧត្តមស្នងការអង្គការសហប្រជា ជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាខេត្តកំពង់ចាម ព្រមទាំងអង្គការនានានៅកំពង់ចាមដោយចោទប្រកាន់មកលើបុគ្គលិកអង្គការសិទ្ធិមនុស្សថាបានញុះញង់អោយប្រជារាស្ត្រធ្វើពាក្យប្តឹងអង្គភាពយោធា ចំពោះការដោះស្រាយបញ្ហាជំលោះដីធ្លីរបស់ពួកគេនៅក្នុងស្រុកត្បូងឃ្មុំ ។ |
| ២០០០ មិនា | បុគ្គលិកអង្គការលីកាដូត្រូវបានគំរាមចាប់ខ្លួន ក្រោយពីបានជួយធ្វើអន្តរាគមន៍ករណីកម្មរោងចក្រកាត់ដេរ ដែលត្រូវបានគេជួញដូរពីប្រទេសវៀតណាមមកកម្ពុជា ។ បុគ្គលិកម្នាក់ក៏ត្រូវបាននគរបាលឃុំខ្លួនអស់មួយរយៈពេលខ្លី ។ |
| ២០០០ មិនា | នៅខេត្តកោះកុងបុគ្គលិកអាដហុកត្រូវបានគេគំរាមចាប់ខ្លួនក្រោយពីបានធ្វើអន្តរាគមន៍ក្នុងករណីជួញដូរមួយ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំអាស៊ីបានរាយការណ៍ថា "ស្ត្រីម្នាក់ដែលលក់កូនរបស់ខ្លួនបានចោទប្រកាន់អ្នកសម្របសម្រួលអាដហុក ប្រចាំខេត្តពីបទបង្ករបួសស្នាមលើរូបរាងកាយ ។ ក្រោយមកស្ត្រីរូបនោះបានដកពាក្យបណ្តឹងរបស់ខ្លួន ហើយបានសារភាពថាខ្លួនធ្វើបែបនេះដោយសារមានការគាបសង្កត់ពីសំណាក់នគរបាលអោយនាងធ្វើបណ្តឹងបែបនេះ[១៦] ។ |
| ២០០០ មិថុនា | បុគ្គលិកឧត្តមស្នងការអង្គការសហប្រជាជាតិពីរនាក់ត្រូវបានគេគំរាមកំហែង ដោយផ្ទាល់មាត់ក្រោយពីបានឃ្លាំមើលបាតុកម្មរបស់កម្មករកាត់ដេរនៅឫស្សីកែវ ភ្នំពេញ និងក្រោយពីព្យាយាមប៉ុនប៉ងស្វែងរកពត៌មានពីកងរាជអាវុធហត្ថដែលជាអ្នកបញ្ជាកំលាំងឈរជើងនៅទីនោះ ។ |
| ២០០០ សីហា | នៅពេលដែលបុគ្គលិករបស់គណកម្មការប្រព្រឹត្តិកម្ម និងបុគ្គលិកឧត្តមស្នងការអង្គការ |

[16] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ឆ្នាំ ២០០២ ។ របាយការណ៍ពិភពលោក : ព្រឹត្តិការណ៍ឆ្នាំ ២០០១ ទំព័រ ៤ ។

| | |
|---|---|
| | សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅ កម្ពុជាកំពុងស៊ើបអង្កេតករណីឃាតកម្មនៅខេត្តក្រចេះ ឆ្នាំ ២០០០ បុគ្គលិកការពារសិទ្ធិមនុស្សម្នាក់ត្រូវបានរងការបំភិតបំភ័យពីសំណាក់អាជ្ញាធរដែនដីដោយសកម្មភាពបំភិតបំភ័យនោះរួមមានការតាមឃ្លាំមើល និងទទួលការគំរាមដោយផ្ទាល់ពីសំណាក់ទាហ៊ាន ។ |
| ២០០០ កញ្ញា | អភិបាលស្រុកនៅខេត្តកំពតបានបញ្ជាអោយបិទការហ្វឹកហ្វឺនអ្នកបោះឆ្នោតដែលហ្វឹកហ្វឺនដោយ COMFREL ដែលជាអង្គការ សង្កេតមើលការបោះឆ្នោត ។ អភិបាលស្រុកបានលើកឡើងថា អង្គការនោះពុំមានការអនុញ្ញាតជាលាយល័ក្ខអក្សរដើម្បីបើកវគ្គមកធ្វើជាមូលហេតុនៃការបិទវគ្គហ្វឹកហ្វឺននោះ ។ |
| ២០០០តុលា | ទាហ៊ានមួយក្រុមបានគំរាមដោយភ្ជង់កាំភ្លើងដាក់បុគ្គលិកឧត្តមស្នងការនោះ ។ នៅពេលដែលបុគ្គលិកឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សចូលធ្វើអន្តរាគមន៏ក្នុងករណីទាហ៊ានបានគំរាមកំហែងសមាជិកសភាគណបក្សសម រង្ស៊ី ។ |
| ២០០០ ធ្នូ | នាយករដ្ឋមន្ត្រីបានចោទប្រកាន់ថាអង្គការសិទ្ធិមនុស្សបានជុំរុញអោយមានអំពើភេរវកម្ម ដោយចោទថាបានផ្តល់ជំរកជ្រកនៅ និងជួយឧបត្ថមដល់ក្រុមភេរវករ ក្រោយពីមានហេតុការវាយប្រហារមិនបានសំរេចដោយក្រុមអ្នកច្បាំង ដើម្បីសេរីភាពកម្ពុជា (CFF) ក្នុងខែ វិច្ឆិកា ឆ្នាំ ២០០០ នៅភ្នំពេញរួចមក ។ នាយករដ្ឋមន្ត្រីបានប្រើភាសាគំរាមកំហែងនេះដើម្បីធ្វើជាការព្រមាន ដល់បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលទាំងឡាយអោយដឹងថា "ពួកគេមិនអាចគេចផុតពីការចាប់ចងបានឡើយ "[១៧] ។ |
| ២០០១ មករា | នៅពេលដែលអង្គការក្លូបលវីតណេស ដែលជាអង្គការមានគោលការណ៍ឃ្លាំមើលព្រៃ |

[17] Cambodia Dail 2000, (បកប្រែក្រៅផ្លូវការ) "ហ៊ុន សែន ថ្លែងនៅខេត្តពោធិសាត់" ទី ៥ ធ្នូ ។ សូមអាន Cambodia Daily 2000 ផងដែរ " នាយករដ្ឋមន្ត្រីព្រមានថា កុំលាក់ CFF" ដោយ ហម សំណាង ទី៦ ធ្នូ ។ ដំណឹងពេលល្ងាច ឆ្នាំ ២០០០ សរសេរថា " សម្តចនាយករដ្ឋមន្ត្រីបានអំពាវនាវដល់អង្គការ កុំការពារភេរវជន "- ដំណឹងពេល ល្ងាច Vol 5, # 680 ។ រស្មីកម្ពុជាឆ្នាំ ២០០០ សរសេរថា " ហ៊ុន សែន បានព្រមានដល់បុគ្គលិកសិទ្ធិមនុស្សកុំអោយលាក់ភេរវជន " ថ្ងៃព្រហស្បត៍ទី ៧ធ្នូ ។ សំលេងយុវជន ឆ្នាំ ២០០០ " ហ៊ុនសែនគំរាមដាក់ខ្នោះបុគ្គលិកសិទ្ធិ មនុស្ស និងប្រធានគណបក្សប្រឆាំង " ថ្ងៃទី ៦ ធ្នូ ។ Associated Press 2000," ហ៊ុន សែន ព្រមានក្រុមសិទ្ធិ មនុស្ស ក្នុងខណៈពេលមានការចាប់ចងនៅធ្វើបន្ត " ថ្ងៃទី ៥ ធ្នូ ។

| | |
|---|---|
| | ឈើជាផ្លូវការបានចេញផ្សាយរបាយការណ៍ស្ដីអំពីការកាប់បំផ្លាញព្រៃឈើយ៉ាងអនាធិប្បតេយ្យនៅមុនកិច្ចប្រជុំអ្នកផ្ដល់ជំនួយអន្តរជាតិ នាយករដ្ឋមន្ត្រីបានគំរាមបណ្ដេញក្រុមនេះអោយចេញពីកម្ពុជា ។ ក្រោយមកដោយមានការគាបសង្កត់ពីសំណាក់ក្រុមអ្នកផ្ដល់ជំនួយទើបគាត់មិនបានអនុវត្តន៍តាមការគំរាមនោះវិញ ។ |
| ២០០១ មករា | តុលាការខេត្តកណ្ដាលបានកោះអញ្ជើញមន្ត្រីអង្គការក្លូបលវីតណេសពីរនាក់ដោយចោទប្រកាន់ពួកគេពីបទរំលោភលើសិទ្ធិបុគ្គល ។ ព្រះរាជអាជ្ញាបានប្រាប់ពួកគេទាំងពីរនាក់នោះថាការត្រួតពិនិត្យរោងចក្រក្ដារបន្ទះរបស់មន្ត្រីទាំងពីរនោះ នឹងអាចនាំអោយមានការចោទប្រកាន់បានតាមមាត្រា ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលទាក់ទងទៅនឹងការរំលោភលើសិទ្ធិបុគ្គល ។ ការចោទប្រកាន់ដោយរំលោភនោះបណ្ដាលមកពីការភ្ញាក់ផ្អើលក្នុងការឃ្លាំមើលដំណើរការរោងចក្រក្ដារបន្ទះ ។ មន្ត្រីអង្គការក្លូបលវីតណេសមិនត្រូវបានគេអនុញ្ញាតអោយចូល ហើយថែមទាំងត្រូវសន្តិសុខឃុំខ្លួនអស់រយះពេល ៦ ម៉ោង ។ ក្រោយមកមន្ត្រីនាយកដ្ឋានរុក្ខាប្រមាញ់បានមកដល់ទើបគេអនុញ្ញាតអោយមន្ត្រីក្លូបលវីតណេសចូលក្នុងរោងចក្រ ហើយពួកគេបានរកឃើញឈើខុសច្បាប់ដែលអត់មានបោះត្រាទាំងនៅខាងក្នុង និងខាងក្រៅរោងចក្រ ។ |
| ២០០១ មិនា | ជនល្មើសមិនស្គាល់អត្តសញ្ញាណម្នាក់បានទាត់ធាក់ទ្វាររបងការិយាល័យកណ្ដាលអង្គការ Vigilance ដែលជាអង្គការសិទ្ធិមនុស្សមួយនៅភ្នំពេញយ៉ាងហឹង្សាជាទីបំផុតធ្វើអោយបុគ្គលិក ៣ នាក់ដែលកំពុងសំរាកនៅក្នុងអគារនោះបានភ្ញាក់ដឹងខ្លួនឡើង ។ ដោយមិនអាចចូលទៅក្នុងបានជននោះបានទាញផ្លាកអង្គការទំលាក់ចុះហើយជាន់ទន្រ្ទាំលើផ្លាកបន្ទាប់មកទៅអង្គុយរង់ចាំនៅក្នុងរថយន្តជាមួយនឹងជនមិនស្គាល់អត្តសញ្ញាណម្នាក់ទៀត ។ |
| ២០០១ មិនា | បុគ្គលិកដ៏ឆ្នើមម្នាក់របស់អង្គការគំរោងការពារជនក្រីក្រដែលជាអង្គការមួយផ្ដល់សេវាផ្នែកច្បាប់ដល់ជនក្រីក្រត្រូវបានជនមិនស្គាល់មុខម្នាក់ដេញតាម និងលួចថតរូបភាពគាត់ ។ |
| ២០០១ ឧសភា | តុលាការក្រុងភ្នំពេញបានធ្វើការចោទប្រកាន់នាយកស្ដីទីលីកាដូពីបទឃុំឃាំងមនុស្សខុសច្បាប់ ។ ករណីនោះគឺពាក់ព័ន្ធទៅនឹងការរំដោះកុមារីរងគ្រោះដោយនគរបាល ព្រមទាំងប្រគល់កុមារីនោះមកលីកាដូដើម្បីថែទាំព្យាបាលបណ្ដោះអាសន្នសិន ។ ឪពុកម្ដាយចិញ្ចឹមរបស់កុមារីនោះបានប្ដឹងបកលីកាដូពីបទឃុំឃាំងមនុស្សខុសច្បាប់ នេះក៏ |

| | |
|---|---|
| | ព្រោះតែលីកាដូបានផ្តល់ជម្រកស្នាក់នៅបណ្តោះអាសន្ន និងការព្យាបាលដល់កុមារីរងគ្រោះនោះ ។ តាមការពិតគឺកំលាំងនគរបាលមូលដ្ឋានជាអ្នករំដោះយកកុមារីនោះចេញពីឪពុម្តាយចិញ្ចឹមនោះ ។ ម្តាយចិញ្ចឹមរូបនោះត្រូវបានតុលាការផ្តន្ទាទោសនិងកាត់ក្តីពីបទរំលោភលើសិទ្ធិកុមារ ស្របពេលគ្នានោះតុលាការក៏បានទទួលបណ្តឹងរបស់ឪពុកម្តាយចិញ្ចឹម ហើយបានធ្វើការចោទប្រកាន់នាយកស្តីទីលីកាដូ ។ ក្រោយមកករណីនោះត្រូវបានលើកលែងការចោទប្រកាន់ ។ ករណីនេះបានធ្វើអោយអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិមានការខ្វាយខ្វល់យ៉ាងខ្លាំងចំពោះការគំរាមកំហែងនេះ ដែលអាចមានគោលបំណងបង្អាក់បន្ថយនូវសកម្មភាពជួយជនរងគ្រោះដោយមូលហេតុសិទ្ធិមនុស្សរបស់លីកាដូ ។ |
| ២០០១ កញ្ញា | បុគ្គលិកលីកាដូត្រូវបានជនល្មើសតាមយ៉ាងហោចណាស់ ៤ ដង ក្នុងខណៈដែលពួកគេកំពុងស៊ើបអង្កេតករណីជួញដូរមួយ ។ ដោយមានការលបតាមឃ្លាំមើលដល់ផ្ទះជនរងគ្រោះ ការិយាល័យលីកាដូ និងតាមដល់ផ្ទះអ្នកស៊ើបអង្កេតទៀតផង ។ |
| ២០០១ ធ្នូ | មានការឃុំខ្លួននិងបំភិតបំភ័យដល់បុគ្គលិកសមាគមខ្មែរកម្ពុជាក្រោមដែលប្រព្រឹត្តិដោយអាជ្ញាធរ ខេត្តកំពង់ធំ ក្នុងខណៈពេលបុគ្គលិករូបនោះធ្វើការស៊ើបអង្កេតអំពីករណីបំផ្លិចបំផ្លាញឧបករណ៏នេសាទក្នុងទ្រង់ទ្រាយធំមួយ ។ |
| ២០០២ មិនា | នគរបាលនិងជនជាតិវៀតណាមបានគំរាមកំហែងដល់បុគ្គលិកអង្គការ UNHCR នៅខេត្តមណ្ឌលគីរី នៅពេលដែលបុគ្គលិករូបនោះបានជួយធ្វើអន្តរាគមន៏តាងនាមអោយអ្នកស្វែងរកសិទ្ធិជ្រកកោនផ្នែកនយោបាយ ។ ជនជាតិវៀតណាមតំបន់ភ្នំប្រមាណ ៥០០ នាក់បានសំដៅទៅរកទីកន្លែងស្នាក់នៅរបស់ពួកអ្នក ស្វែងរកសិទ្ធិជ្រកកោនខាងនយោបាយក្នុងជំរំរបស់អង្គការ UNHCR នៅខេត្តមណ្ឌលគីរី ។ នគរបាលកម្ពុជាបានរុញនាងអោយធ្លាក់ពីលើផ្លូវ ក្នុងខណៈដែលនាងកំពុងរារាំងនគរបាលពីការវាយប្រហារទៅលើផ្ទះរបស់អ្នកបកប្រែភាសាជនជាតិភាគតិចម្នាក់ ។ |
| ២០០២ មិនា | អ្នកបើកបរកាណូតម្នាក់ដែលបើកដឹកជនភៀសខ្លួននៅក្នុងការងារក្រៅផ្លូវការដែលទាក់ទងទៅនឹងអង្គការ UNHCR ក្រោយមកត្រូវបានចាប់ខ្លួនក្រោមការចោទប្រកាន់ពីបទជួញដូរមនុស្ស ។ អ្នកបើកបរនោះពុំមែនជាបុគ្គលិកអចិន្ត្រៃយ៏ ហើយក៏ពុំមានកិច្ចសន្យាជាផ្លូវការណាមួយជាមួយ នឹងUNHCRដែរ ប៉ុន្តែត្រូវបានចោទប្រកាន់ក្រោយពីគាត់បានដឹកជញ្ជូនជនភៀសខ្លួនទាំងនោះដែល UNHCR កំពុងតែរៀបចំ |

| | |
|---|---|
| | កន្លែងស្នាក់នៅដល់ពួកគេ ។ ក្រោយពីត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល ៤ខែ តុលាការបានដោះលែងជននោះវិញនៅ ថ្ងៃទី ១២ ខែសីហា ។ |
| ២០០២ មេសា | ជំរំ UNHCR នៅមណ្ឌលគីរីត្រូវបាននគរបាលកម្ពុជា និងមន្ត្រីវៀតណាមលួចសំភារៈ និងដុតបំផ្លាញចោល។ ប្រហែល ១ម៉ោងក្រោយមករថយន្តដឹកជញ្ជូនរបស់រដ្ឋាភិបាលចំនួន ១៨ គ្រឿងបានដឹកអ្នកភៀសខ្លួនដែលជាអ្នកភ្នំទាំងនោះប្រមាណ ៥៥០ នាក់ចេញសំដៅមកទីក្រុងភ្នំពេញ ។ ជំរំនោះត្រូវបានគេដុតបំផ្លាញចោល រីឯបុគ្គលិក UNHCR ត្រូវជំលៀសចេញទាន់ពេល បរិវេណជំរំទាំងមូលប្រមាណ ៥០% ត្រូវបានដុតបំផ្លាញ ។ |
| ២០០២ មេសា | មន្ត្រីជាន់ខ្ពស់នៃអង្គការត្រួតពិនិត្យព្រៃឈើឯករាជ្យក្លូបលវីតណេស ត្រូវបានវាយនិងទាត់ធាក់អោយដួល ទៅនឹងដីនៅក្បែរការិយាល័យរបស់នាង ព្រមទាំងបានផ្ញើអ៊ីមេលគំរាមនាងថាអោយ " **ឈប់** "។ អង្គការក្លូបលវីតណេសបានចាត់ទុកករណីនេះថាជាល្បិចបំភិតបំភ័យពីសំណាក់អ្នកដែលមានផលប្រយោជន៏ក្នុងរឿងព្រៃឈើ ដែលត្រូវទទួលរងការភ័យខ្លាចពីការស៊ើបអង្កេតដែលលាតត្រដាងនូវបទល្មើសកាប់ព្រៃឈើរបស់ពួកគេទាំងនោះ ថាជាទង្វើខុសច្បាប់ ។ |